ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

**សុន្ទរកថាបិទ**
**របស់លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេស**
**ក្នុងឱកាសសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៤ របស់ធនាគារជាតិនៃកម្ពុជា ស្តីពី**
**"តួនាទីរបស់បច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា"**
ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៧ នៅ សណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីតត្រា
*************

សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាទីមេត្រី!

សន្និសីទរបស់យើងបានឈានមកដល់ទីបញ្ចប់ ប្រកបដោយជោគជ័យនិងផ្លែផ្កា។ តាងនាមឱ្យធនាគារជាតិនៃកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមដ៏សកម្មរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់និងបទពិសោធន៍លើប្រធានបទរបស់សន្និសីទយើងនៅពេលនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះវាគ្មិនយើង ដែលបានខិតខំធ្វើការស្រាវជ្រាវលើប្រធានបទដែលបានធ្វើបទបង្ហាញនាព្រឹកនេះ ក្នុងរយៈពេលជាងប្រាំពីរខែកន្លងមក។

ដូចដែលវាគ្មិនបានធ្វើបទបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវ បច្ចេកវិទ្យាបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ តាមរយៈការកាត់បន្ថយចំណាយប្រតិបត្តិការនិងពេលវេលារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងអតិថិជន ដើម្បីគាំទ្រការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច និងបរិយាប័ន្នហិរញ្ញវត្ថុ។ ការពង្រីកសេវាហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយផ្តល់ឱកាសដល់ក្រុមគ្រួសារ និងសហគ្រាសទទួលបានធនធានហិរញ្ញវត្ថុសម្រាប់ពង្រីកសកម្មភាពអាជីវកម្ម ក្នុងការលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសប្រជាជនក្រីក្រនិងប្រជាជនដែលមានចំណូលទាប។ ស្របតាមការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបង្កើនការប្រើប្រាស់បច្ចេកវិទ្យាក្នុងការផ្តល់សេវាតាមរយៈទូរស័ព្ទចល័ត និងប្រព័ន្ធអ៊ីនធើណែត ជាដើម ដែលបានសម្រួលយ៉ាងច្រើនដល់ការផ្តល់សេវាហិរញ្ញវត្ថុ។ ម៉្យាងលទ្ធផលនៃការស្រាវជ្រាវក៏បង្ហាញថា ការយល់ដឹងពីការប្រើប្រាស់បច្ចេកវិទ្យានិងសេវាហិរញ្ញវត្ថុ ទាមទារឱ្យមានការលើកកម្ពស់បន្ថែម



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដោយចាំបាច់ត្រូវមានការចូលរួមពីរាជរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល សំដៅរួមចំណែកក្នុងការជៀសវាងហានិភ័យ និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។ ខ្ញុំសូមសម្តែងការគាំទ្រចំពោះលទ្ធផលនៃការស្រាវជ្រាវនិងការលើកឡើងជាអនុសាសន៍ ហើយក៏ដូចដែលលោកជំទាវ ទេសាភិបាលរង បានបញ្ជាក់ព្រឹកមិញថា ធនាគារជាតិនៃកម្ពុជាបានតាមដានការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុដោយយកចិត្តទុកដាក់ ជាពិសេស ឥទ្ធិពលមកលើបរិយាប័ន្នហិរញ្ញវត្ថុនិងស្ថិរភាពហិរញ្ញវត្ថុ ព្រមទាំងបាននិងកំពុងពង្រឹងក្របខ័ណ្ឌត្រួតពិនិត្យ បទប្បញ្ញត្តិ និងយន្តការគ្រប់គ្រងហានិភ័យ ពង្រឹងប្រព័ន្ធសុវត្ថិភាពប្រឆាំងនឹងឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាទីមេត្រី!**

ខ្ញុំជឿជាក់ថា សន្និសីទរបស់យើងមួយព្រឹកនេះ រួមចំណែកបង្កើនការយល់ដឹងបន្ថែមទៅលើសារៈសំខាន់និងតួនាទីរបស់បច្ចេកវិទ្យា ក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា។ ខ្ញុំសង្ឃឹមផងដែរថា លទ្ធផលនៃកិច្ចពិភាក្សារបស់យើងនឹងជាធាតុចូលបន្ថែម សម្រាប់ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធបញ្ចូលក្នុងគោលនយោបាយនិងវិធានការរបស់ខ្លួន សំដៅលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។ ទន្ទឹមនេះ កិច្ចពិភាក្សានឹងអាចបើកផ្លូវទៅរកការស្រាវជ្រាវលម្អិតលើប្រធានបទពាក់ព័ន្ធសំខាន់ៗបន្ថែមទៀត នាពេលអនាគត។ ក្នុងន័យនេះ ខ្ញុំសូមលើកទឹកចិត្តដល់សេដ្ឋវិទូនិងអ្នកស្រាវជ្រាវឱ្យបន្តពង្រឹងនិងពង្រីកការស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា ក៏ដូចជាសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន។ ជាមួយគ្នានេះ ដើម្បីបន្តគាំទ្រការស្រាវជ្រាវលើប្រធានបទសំខាន់ថ្មីៗថែមទៀត ខ្ញុំសូមជម្រាបជូនថា ធនាគារជាតិនៃកម្ពុជាគ្រោងនឹងរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៥ សម្រាប់ឆ្នាំ២០១៨ ដែលប្រធានបទនឹងត្រូវកំណត់នាពេលឆាប់ៗនេះ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមសន្និសីទថ្ងៃនេះ។ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន ប្រាជ្ញាវាងវៃ និងមានជ័យជម្នះគ្រប់ភារកិច្ច ។

**សូមអរគុណ!**